# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ថៃបានដុតសម្លាប់យុវជនខ្មែរម្នាក់

website ៖ www.hoksavann.org

ថ្ងៃទី២ តុលា ២០០៩



តាមពត៌មានពីក្រសួងការបរទេសខ្មែរថា ថៃបានដុតសម្លាប់យុវជនខ្មែរម្នាក់អាយុ១៦ឆ្នាំ ក្រោយពេលដែលយុវជននេះជាមួយខ្មែរ១១នាក់ទៀតចូលទៅដីថៃ ។ ក្រសួងការបរទេសខ្មែរបានថ្កោលទោសយ៉ាងខ្លាំងចំពោះអំពើឃោរឃៅនេះ ហើយសុំឲ្យថៃចាប់អ្នកប្រព្រឹត្តអំពើឧក្រិដ្ឋនេះយកទៅកាត់ទោសតាមច្បាប់អន្តរជាតិ ។ អំពើឧក្រិដ្ឋនេះបានកើតឡើងនៅថ្ងៃទី១១ កញ្ញា ២០០៩ ។

ថៃបានចងគំនុំខ្មែរជានិច្ច តាំងពីថៃចាញ់ក្ដីព្រះវិហារឆ្នាំ១៩៦២មក ។ តាមពត៌មានពីខ្មែរដែលរស់នៅប្រទេសថៃជាយូរមកហើយថា នៅពេលដែលថៃចាញ់ក្ដី ថៃបានដេីរចាប់ផ្សឹកព្រះសង្ឃខ្មែរ ដែលរស់នៅប្រទេសថៃជាយូរមកហើយ ។ ព្រះសង្ឃខ្លះត្រូវថៃចាប់ផ្សឹក ព្រះសង្ឃខ្លះបានរត់គេចខ្លួនទៅខេត្តនានានៃប្រទេសថៃ ទោះបីជនជាតិខ្មែរទាំងនេះមានសញ្ជាតិជាថៃហើយក៏ដោយ ។

នេះពុំមែនជាលើកទីមួយទេ ដែលថៃបានសម្លាប់ខ្មែរ ។ នៅពេលខ្មែរបានកើតសង្គ្រាមនៅក្នុងប្រទេសរបស់ខ្លួន ខ្មែរបានភៀសខ្លួនចូលទៅដីថៃ ត្រូវថៃសម្លាប់អស់ច្រើនណាស់ ។ នៅឆ្នាំ១៩៧៩ ដោយភ័យបាក់ស្បាតនឹងរបបខ្មែរក្រហមផង ដោយភ័យខ្លាចវៀតណាមផង ជនជាតិខ្មែរជាច្រើនបានភៀសខ្លួនចូលទៅដីថៃ ។ តាមថេរដីកាពីព្រះសង្ឃមួយអង្គជាជាតិខ្មែរ ដែលគង់នៅប្រទេសថៃថា ថៃបានដឹកអ្នកភៀសខ្លួនខ្មែរតាមរថយន្តជាច្រើន យកទៅសម្លាប់

នៅទីសម្ងាត់មួយនៅប្រទេសថៃ ។ ក្រោយមកទើបប្រែផែនការ បានដឹកខ្មែររាប់រយរថយន្តទៅទម្លាក់ចោលនៅភ្នំព្រះវិហារ ។ ដីភ្នំព្រះវិហារនៅខាងថៃខ្ពស់ជាងខាងដីខ្មែរ ។ ខ្មែរភៀសខ្លួនដែលថៃយកទៅទម្លាក់ បានដើរចុះទៅដីខ្មែរ ខ្លះបានត្រូវជាន់មីន ដាច់ដៃដាច់ជើង ស្លាប់អស់ជាច្រើន ។ នេះជាអំពើអមនុស្សធម៌របស់ថៃ ដែលប្រព្រឹត្តមកលើពលរដ្ឋខ្មែរ ដែលមានទុក្ខនៅក្នុងប្រទេសរបស់ខ្លួន ខំរត់រកកន្លែងសុខ តែត្រូវថៃធ្វើបាបថែមទៀត ដូចជាដឹកយកមកទម្លាក់ចោលឲ្យស្លាប់ដោយគ្រាប់មីននេះ ។

សោកនាដកម្មនេះបានដឹងដល់អន្តរជាតិ អំពីសេចក្តីទុក្ខវេទនារបស់ជនជាតិខ្មែរនេះ ។ អន្តរជាតិមានសហរដ្ឋអាមេរិកជាដើម បានប្រញាប់ប្រញាល់ទាក់ទងនឹងរាជរដ្ឋាភិបាលថៃ សុំជួលដីថៃធ្វើជំរំឲ្យជនជាតិខ្មែរស្នាក់នៅជាប-ណ្តោះអាសន្ន ទំរាំប្រទេសកម្ពុជាបានសន្តិភាព ហើយជាការទប់ដំណើរកុំឲ្យថៃបញ្ជូនខ្មែរទៅទម្លាក់ចោលកន្លែងគ្រោះថ្នាក់ដោយគ្រាប់មីនទៀត ។ ជំរំខៅអ៊ីដាង ជំរំស្រះកែវ បន្ទាប់មកជំរំឆុនបូរីក៏កើតឡើង ។ ការធ្វើដំណើរចូលមកដីថៃរបស់ប្រជាពលរដ្ឋខ្មែរ ក៏ត្រូវទទួលគ្រោះថ្នាក់ដោយចោរថៃ ដោយអ្នកខ្លះដែលសល់របស់របរបន្តិចបន្តួចជាប់មកតាមខ្លួន ដូចជាមាសពេជ្រជាដើម ត្រូវចោរសៀមសម្លុតប្លន់ មានខ្លះត្រូវចោរសៀមសម្លាប់ មានខ្លះត្រូវរបួស បើស្រីខ្មែរវិញ ត្រូវចោរសៀមចាប់រំលោភ ។ នៅតាមជំរំដែលអ្នកភៀសខ្លួនខ្មែរស្នាក់នៅ ថៃឲ្យទាហានប្រើអាជ្ញាសឹក ។ ដោយសារផែនការនេះហើយ បានជាគេឃើញពេលខ្លះ ថៃបានបាញ់សម្លាប់ប្រជាពលរដ្ឋខ្មែរ នៅពេលដែលពួកគេបានចេញផុតពីរបងការពារ ដើម្បីទៅរកបេះបន្លែ ឬទៅរកអុស ឬដើម្បីទៅទិញដូររបស់ផ្សេងៗ ។ ដោយសារអ្នកភៀសខ្លួនខ្មែរ ថៃបានចំណេញច្រើនណាស់ ចំណេញដោយការជួលដី ដោយជំនួយដល់អ្នកភៀសខ្លួន ត្រូវស្ថិតនៅលើការចាត់ចែងរបស់ថៃ ដូចជាចំណីអាហារ ថៃបានទិញរបស់ថោកៗ ដូចជាត្រីផ្អាធូជាដើម ។ នៅឆុនបូរី ជប៉ុនបានធ្វើមន្ទីរពេទ្យសំរាប់ព្យាបាលអ្នកភៀសខ្លួន លុះអ្នកភៀសខ្លួនខ្មែរចេញផុតពីថៃ មន្ទីរពេទ្យនោះជាកម្មសិទ្ធិរបស់ថៃ ។ អ្នកភូមិថៃនៅក្បែរនោះ ទៅជាមានសម្បត្តិធូរធា ដោយការលក់ដូរទំនិញជាមួយអ្នកភៀសខ្លួនខ្មែរ ។

ថៃគាំទ្រចលនាតស៊ូខ្មែរដែលប្រឆាំងវៀតណាមចូលមកកាន់កាប់ប្រទេសកម្ពុជា ការពិតពុំមែនថៃអាណិតអាសូរដល់ជនជាតិខ្មែរទេ តែថៃទុកចលនាតស៊ូត្រីភាគីខ្មែរក្នុងអំឡុងឆ្នាំ១៩៨០នោះ ជារបងការពារកុំឲ្យវៀតណាមចូលមកឈ្លានពានប្រទេសថៃបាន ព្រោះផែនការរបស់ហូ-ជីមិញ កាលណាយកប្រទេសលាវនិងខ្មែរបានហើយ នឹងបន្តយកប្រទេសថៃទៀត ហើយថៃធ្វើតាមនយោបាយចិនកុម្មុយនិស្តក្នុងបញ្ហាខ្មែរផង ។

តាមប្រវត្តិសាស្ត្រ ថៃបានចូលមកឈ្លានពានប្រទេសកម្ពុជាជាញឹកញាប់ ។ ដោយការឈ្លានពានរបស់ប្រទេសថៃនិងវៀតណាមជាញឹកញាប់បែបនេះហើយ ទើបព្រះមហាក្សត្រខ្មែរសុំប្រទេសបារាំងឲ្យជួយការពារនៅឆ្នាំ១៨៦៣ ។ ក្រោយមកប្រទេសបារាំងបានធ្វើអាណានិគមនិយមលើប្រទេសកម្ពុជា រហូតបាត់ឯករាជ្យ ។ ថៃទើបកើតជាប្រទេសនៅពាក់កណ្តាលសតវត្សរ៍ទី១៨ មានព្រំដែនជាប់នឹងប្រទេសកម្ពុជាប្រវែង៨០៣គីឡូម៉ែត្រ ។ មានប្រជាជនចំនួនជាង៦៥លាននាក់ ។ មានទឹកដីទំហំ៥១៥,០០០គ.ម២ ។ ខ្មែរបានត្រូវបាត់បង់ទឹកដីទៅថៃអស់ជាច្រើនខេត្ត ។

ថៃទើបនឹងកើតជាប្រទេសនៅពាក់កណ្តាលសតវត្សរ៍ទី១៨ ឯប្រាសាទព្រះវិហារកើតឡើងតាំងពីសតវត្សរ៍ទី១១ ។ ថៃថាប្រាសាទព្រះវិហារជាប្រាសាទរបស់គេ ។ បន្ទាប់ពីអង្គការយូនេស្កូបានដាក់ប្រាសាទព្រះវិហារជាសម្បត្តិរបស់ពិភពលោកមក ថៃក្តៅក្រហាយជាខ្លាំង បានបង្កហេតុនៅតាមព្រំប្រទល់ដែនជិតប្រាសាទព្រះវិហារ ។ បានបាញ់ចូលមកដីខ្មែរ ធ្វើឲ្យស្លាប់និងរបួសទាហានខ្មែរជាច្រើននាក់ ។ ឥឡូវនេះ ថៃកំពុងមានភាពវឹកវរក្នុងប្រទេសបស់ខ្លួនដោយគណបក្សប្រឆាំងគ្នា ។ ប៉ុន្តែភាពល្អមួយរបស់ថៃ នៅត្រង់ថៃទាស់គ្នាយ៉ាងណាក៏ដោយ ក៏ថៃមិនដែលពឹងបរទេសឲ្យជួយកំចាត់គ្នាដូចខ្មែរឡើយ ។ ភាពវឹកវរមួយទៀត គឺជនជាតិថៃមានដើមកំណើតម៉ាឡេស៊ីកាន់សាសនាឥស្លាមចំនួនបីខេត្តនៅប៉ែកខាងត្បូងនៃប្រទេសថៃ ចង់បំបែកទឹកដីរបស់ខ្លួនចេញពីថៃ កំពុងបះបោរបង្កើតភេរវកម្មផ្ទុះគ្រាប់បែកស្លាប់ប្រជាជនថៃស្ទើររាល់ថ្ងៃ។ ពេលនេះទំនងជាថៃទទួលទុក្ខវេទនាម្តងវិញ ដោយសារតែថៃបានសាងបាបកម្មមកលើប្រជាពលរដ្ឋខ្មែរប្រាសចាកមនុស្សធម៌ ។ ថៃកាន់ព្រះពុទ្ធសាសនា

ប៉ុន្តែថៃដាច់សីលអទិន្នាទាន រំលោភយកដីរបស់ខ្មែរ ។ ដាច់សីលបាណាតិបាត ដោយថៃសម្លាប់ប្រជាពលរដ្ឋខ្មែរ ដូចដុតទាំងរស់នូវយុវជនខ្មែរម្នាក់ ដែលមានអាយុ១៦ឆ្នាំ ដូចក្នុងប្រធានបទនេះ ។

ជាអកុសល ប្រទេសខ្មែរស្ថិតនៅលើទឹកដីមួយ ដែលប្រទេសសងខាងពីរ គឺវៀតណាមនិងថៃ ចេះតែមានមហិច្ឆិតាចង់បានទឹកដីខ្មែរជាប់ជានិច្ច ហើយទឹកដីបានត្រូវបាត់បង់អស់ជាច្រើនទៅប្រទេសទាំងពីរនេះ ។ ចលនាពង្រីកទឹកដីនេះ ចេះតែមានជាបន្តទៅទៀត បើខ្មែរមិនប្រុងប្រយ័ត្នទេ អាចបាត់បង់ទឹកដីដែលនៅសេសសល់តិចតួចនេះថែមទៀត ។ សន្ធិសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាដែលខ្មែរនិងវៀតណាមបានចុះហត្ថលេខា មានភាពពុំស្មើគ្នា ដោយវៀតណាមពេលនោះមកត្រួតត្រាលើប្រទេសកម្ពុជា តើសន្ធិសញ្ញានោះមានភាពត្រឹមត្រូវ ខ្មែរមិនបាត់បង់ទឹកដីទេឬ ? មួយទៀតផែនការថ្មីរបស់វៀតណាម ចេះតែឲ្យប្រជាជនគេចូលមកក្នុងទឹកដីខ្មែរខុសច្បាប់កាន់តែច្រើនឡើងៗ ដោយគ្មានការត្រួតពិនិត្យបែបនេះ តើអនាគតខ្មែរអាចទៅជាជនជាតិភាគតិចនៅស្រុកកំណើតរបស់ខ្លួន ដោយវៀតណាមចូលមករស់នៅកម្ពុជាច្រើនជាងក្លាយជាការពិតឬទេ ? ។ បញ្ហាទឹកដីនិងប្រាសាទព្រះវិហារ ដែលថៃបង្កើតឲ្យមានបញ្ហានេះ តើការចរចាទ្វេភាគី ដល់ទីបំផុតទៅបានផលបែបណា ? បើមិនពឹងច្បាប់អង្គការសហប្រជាជាតិទេ ។

ព្រះពុទ្ធសាសនាសំដែងអំពីអបរិហានិយធម៌ ប្រែថាធម៌មិនធ្វើឲ្យមានសេចក្តីវិនាសថា ប្រទេសមួយទោះបីតូចក៏ដោយ បើចេះរួបរួមគ្នា ឧស្សាហ៍ប្រជុំគ្នារឿយៗ ពិគ្រោះគ្នាអំពីបញ្ហាស្រុកទេស ចេះស្តាប់គ្នាទៅវិញទៅមក ចេះយកយោបល់ពីចាស់ទុំអ្នកធ្លាប់មានការពិសោធន៍ មកពិចារណាថ្លឹងថ្លែងមើល ហើយនាំគ្នាគោរពច្បាប់ទម្លាប់ឲ្យបានត្រឹមត្រូវ ប្រទេសនោះអាចការពារខ្លួនបាន ប្រទេសដទៃនោះទោះបីធំមានឥទ្ធិពលយ៉ាងណាក៏ដោយ ក៏ពុំអាចចូលមកឈ្លានពានប្រទេសដែលគេរួបរួមគ្នាបានឡើយ ។ យ៉ាងណាមិញ ប្រទេសកម្ពុជា បើម្ខាងៗកុំឲ្យមានបរទេសនៅពីក្រោយជាបង្អែកដើម្បីកំចាត់គ្នាទេ ប្រទេសដ៏តូចនេះនឹងអាចស្ថិតនៅជាប្រទេសបាន ។ នេះជាការអធិប្បាយពង្រីកប្រធានបទ ដែលថាខ្មែរធ្វើឲ្យថៃមើលងាយ របូតដុតសម្លាប់ប្រជាជនខ្លួនបែប

នេះ មកអំពីខ្មែរមិនរួបរួមគ្នាឲ្យមានឯកភាពជាតិ ចេះតែលួចសម្លាប់គ្នា ធ្វើឲ្យប្រទេសក្រីក្រលំបាករត់ទៅរកស៊ីស្រុកគេ នាំឲ្យគេមើលងាយបែបនេះឯង ។

❄ ❄

❄